Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

# សេចក្តីជូនដំណឹង

**គណៈកម្មាធិការ ខុមហ្វ្រែល** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបថា គណៈកម្មាធិការ ខុមហ្វ្រែល នឹងរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតស្តីពី "**ការកំណត់តម្រូវការជាអាទិភាពនៅឃុំ សង្កាត់ដាច់ស្រយាល**" ចំនួន ១០ នៅតាមទីកន្លែងដោយឡែកៗពីគ្នា។

សិក្ខាសាលានេះ មានគោលបំណង បង្កើនការយល់ដឹងដល់ម្ចាស់ឆ្នោតអំពីសិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោត ក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋាន និងបង្កើនឱកាសឱ្យម្ចាស់ឆ្នោតចូលរួមក្នុងការពិភាក្សាដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ សង្កាត់របស់ខ្លួន ហើយតម្រូវការជាអាទិភាពទាំងនេះ នឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សក្នុងឃុំ។

ខុមហ្វ្រែល នឹងអញ្ជើញវាគ្មិនជាក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងតំណាងអង្គការសង្គមស៊ីវិល ឬប្រធានសហគមន៍ដើម្បីចាប់អារម្មណ៍ទៅលើតម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ដែលបានលើកឡើងដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ សម្រាប់ផ្តល់ជូនគណបក្សនយោ-បាយ និងមន្ត្រីជាប់ឆ្នោតបំពេញ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី នាងកញ្ញាតំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

## ទីកន្លែង និងកាលបរិច្ឆេទ សិក្ខាសាលាសម្លេងម្ចាស់ឆ្នោត

| ល.រ | ថ្ងៃខែឆ្នាំរៀបចំ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | រាជធានី/ខេត្ត | ឈ្មោះទំនាក់ទំនង | ទូរសព្ទ |
|---|---|---|---|---|---|---|
| ១ | ១១/០៥/២០១១ | ចាន់មូល | មេមត់ | កំពង់ចាម | **លោក ញឹក សុភ** | ០១១ ៥៨៩ ២៧៩ |
| ២ | ១២/០៥/២០១១ | ជាំ | | | | |
| ៣ | ១២/០៥/២០១១ | ក្រយា | កំពង់ស្វាយ | កំពង់ធំ | **អ្នកស្រី រ៉ែន ម៉ាឌីណា** | ០៩៧ ៧២៧៧ ៣២៣ |
| ៤ | ១៦/០៥/២០១១ | ដូង | ប្រាសាទបល្ល័ង្គ | | | |
| ៥ | ២៥/០៥/២០១១ | កំពង់គោ | | | | |
| ៦ | ២៤/០៥/២០១១ | ល្វែងឫស្សី | ជីក្រែង | សៀមរាប | **លោក ផល ម៉ិនត** | ០៩២ ៦៧៦ ៩៨១ |
| ៧ | ២៦/០៥/២០១១ | ល្វាក្រាំង | វ៉ារិន | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | ១០/០៥/២០១១ | កំពង់ស្រឡៅមួយ | ឆែប | ព្រះវិហារ | **អ្នកស្រី លន់ ស៊ីថាន់** | ០១២ ៨៩១ ៦២៧ |
| ៩ | ១៨/០៥/២០១១ | ធ្នា | ជ័យសែន | | | |
| ១០ | ២៥/០៥/២០១១ | រក្សា | រវៀង | | | |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់ !*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែ ឧសភា ឆ្នាំ ២០១១*

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖** លោកស្រី ៖ **ហេង សុគន្ធា** (០១៧ ៥៨៣ ៨៦៩)